# ការជួយដល់អ្នកដទៃឱ្យស្គាល់ការខ្សឹបប្រាប់នៃព្រះវិញ្ញាណ

វីហ្គី អែហ្វ ម៉ាតស៊ូមូរី
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានអង្គការបឋមសិក្សាទូទៅ

*យើងអាចជួយដល់អ្នកដទៃឱ្យកាន់តែស្គាល់ការបំផុសគំនិតនៃព្រះវិញ្ញាណ នៅពេលយើងចែកចាយទីបន្ទាល់របស់យើងអំពីឥទ្ធិពលនៃព្រះវិញ្ញាណ បរិសុទ្ធនៅក្នុងជីវិតរស់នៅរបស់យើង ។*

ពេលចប់ការងាររបស់ពួកគេ អ្នកផ្សព្វផ្សាយសាសនាមួយគូ ចាប់ផ្ដើមដើរទៅផ្ទះ រំពេចនោះមានម្នាក់ងាកទៅរកដៃគូ ហើយនិយាយថា "ខ្ញុំមានអារម្មណ៍ថា យើងចាំបាច់ត្រូវឈប់នៅកន្លែងចុងក្រោយមួយនេះ" ។ គ្រូបង្រៀនតាមផ្ទះម្នាក់ត្រូវបានបំផុសគំនិតឱ្យទូរស័ព្ទទៅកាន់គ្រួសារមួយ ដែលគាត់បានជួបកាលពីប៉ុន្មានថ្ងៃមុន ។ យុវនារីម្នាក់រៀបផែនការថាចូលរួមក្នុងពិធីជប់លៀងរបស់មិត្តនៅសាលានាង ប៉ុន្ដែមានអារម្មណ៍ថាលើកនេះត្រូវនៅផ្ទះម្ដង ។

តើអ្នកផ្សព្វផ្សាយសាសនាដឹងថាត្រូវគោះទ្វាររបស់នរណាម្នាក់ដែលកំពុងតែអធិស្ឋានរកពួកគេដោយរបៀបណា? ឬ តើគ្រូបង្រៀនតាមផ្ទះ ដឹងថាត្រូវទូរស័ព្ទទៅគ្រួសារមួយ ដែលត្រូវការជំនួយយ៉ាងខ្លាំងដោយរបៀបណា? ឬ តើយុវនារីអាចដឹងថាត្រូវនៅឆ្ងាយ ពីស្ថានភាព ដែលអាចនឹងបន្ទាបដល់តម្លៃរបស់នាងដោយរបៀបណា? នៅក្នុងស្ថានភាព នីមួយៗទាំងនេះ ពួកគេត្រូវបានដឹកនាំដោយឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។

បទពិសោធន៍ស្រដៀងគ្នា កើតឡើងដដែលៗចំពោះសមាជិកនៅទូទាំងពិភពលោកជារៀងរាល់ថ្ងៃ ហើយមានមនុស្សដែលមានបំណងប្រាថ្នា ដើម្បីទទួលអារម្មណ៍ នៃព្រះវិញ្ញាណដឹកនាំពួកគេជាប្រចាំនៅក្នុងជីវិតរស់នៅ ។ ខណៈពេលមនុស្សម្នាក់ៗ អាចរៀនស្គាល់ការខ្សឹបប្រាប់នៃព្រះវិញ្ញាណ ដំណើរការនៃការរៀនសូត្រនោះ អាចនឹងត្រូវបាន ធ្វើឱ្យកាន់តែងាយស្រួល នៅពេលអ្នកដទៃជួយយើងឱ្យយល់អំពីព្រះវិញ្ញាណបរិសុទ្ធ ចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនពួកគេ ហើយផ្ដល់បរិយាកាសមួយ ដែលអាចទទួលអារម្មណ៍ព្រះវិញ្ញាណ ។

## ការយល់គោលលទ្ធិ

សារៈសំខាន់នៃការជួយដល់អ្នកដទៃឱ្យយល់ គឺត្រូវបានពិពណ៌នានៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ។ ឪពុកម្ដាយ "នៅក្នុងស៊ីយ៉ូន ឬនៅក្នុងស្តេកណាមួយ ដែលបានរៀបចំឡើង" ត្រូវបានប្រាប់ឱ្យជួយដល់កូនចៅរបស់ពួកគាត់ "យល់នូវគោលលទ្ធិ" ។ 1

មិនថាយើងស្ថិតនៅក្នុងថ្នាក់រៀន ក្នុងការពិភាក្សាអ្នកផ្សព្វផ្សាយសាសនា ឬក្នុងរាត្រីជួបជុំក្រុមគ្រួសារនោះទេ ការបង្រៀនគោលលទ្ធិស្ដីអំពីព្រះវិញ្ញាណបរិសុទ្ធ អាចជួយដល់អ្នកដទៃឱ្យយល់អំពីអំណោយទានសំខាន់នេះ ។ យើងដឹងថាខណៈពេល "ព្រះវិញ្ញាណនៃព្រះគ្រីស្ទត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឱ្យគេអាចដឹងខុស និងត្រូវ" 2 សិទ្ធិដើម្បីមានភាពជាដៃគូនៃ

ព្រះវិញ្ញាណបរិសុទ្ធខ្ជាប់ខ្ជួន កើតមាន នៅពេលសមាជិកត្រូវបានប្រទានឱ្យនូវអំណោយទាននោះ ដោយការដាក់ដៃនៅលើក្បាល ដោយអ្នកទាំងឡាយដែលមាន សិទ្ធិអំណាចត្រឹមត្រូវ។3

ភាពជាដៃគូនេះ អាចបន្តនៅជាមួយយើង បើសិនជាយើងមានភាពសក្តិសម។ យើងត្រូវបានប្រាប់ថា "ព្រះវិញ្ញាណនៃព្រះអម្ចាស់ ពុំគង់នៅក្នុងព្រះវិហារណាដែលឥត បរិសុទ្ធឡើយ។ 4 ហើយថា នៅពេលយើង "ឱ្យគុណធមិតុបតែងគំនិត [របស់យើង] ដោយឥតឈប់ឈរ នោះ...ព្រះវិញ្ញាណបរិសុទ្ធនឹងទៅជាគូកន [របស់យើង] ជានិច្ច"។5

ព្រះគម្ពីរ និងពួកព្យាការីបង្រៀនអំពីភាពជាដៃគូខ្ជាប់ខ្ជួននេះជាអ្វីខ្លះ។ ព្រះអម្ចាស់ប្រាប់យើងថា "យើងនឹងប្រាប់អ្នក នៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងសណ្ឋិតមកលើអ្នក ហើយដែលនឹងគង់នៅក្នុង ចិត្តរបស់ អ្នក" 6 អេណុស បានថ្លែងថា "នៅពេលខ្ញុំ...កំពុងសញ្ជឹងក្នុងវិញ្ញាណ មើលចុះសម្លេងនៃព្រះ អម្ចាស់បានចូលមកក្នុង គំនិត ខ្ញុំ" 7 យ៉ូសែបស្ម៊ីធមានប្រសាសន៍ថា "នៅពេលអ្នកទទួលអារម្មណ៍មាន បញ្ញាបរិសុទ្ធនៅក្នុងខ្លួនអ្នក វាអាចផ្តល់នូវគំនិត មួយរំពេចដល់អ្នក"។8 ប្រធាន ហិនរី ប៊ី អាវរិង បានពិពណ៌នាអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធថាជា "សេចក្តីសុខសាន្ត សេចក្តី សង្ឃឹម និង សេចក្តីអំណរ"។ លោកបន្ថែមទៀតថា "ខ្ញុំស្ទើរតែមានការទទួលអារម្មណ៍ នៃពន្លឺជានិច្ច"។9

ការពិពណ៌នាដែលជាទីពេញចិត្តរបស់ខ្ញុំ ចេញមកពីក្មេងប្រុសអាយុប្រាំបីឆ្នាំម្នាក់ ដែលទើបតែបាន ទទួលព្រះវិញ្ញាណបរិសុទ្ធ។ គាត់ និយាយថា "គាត់មានអារម្មណ៍ដូចជាពន្លឺព្រះអាទិត្យ"។

**ចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន**

ទោះជាយ៉ាងណាក៏ដោយ វាមិនមែនជានិច្ចកាលងាយស្រួលដើម្បីដឹងអំពី "ពន្លឺព្រះអាទិត្យ" ភ្លាមនៅពីដំបូងនោះទេ។ ព្រះគម្ពីរមរមន ប្រាប់យើងអំពីពួកសាសន៍លេមិន ស្មោះត្រង់មួយចំនួនដែល "ត្រូវបានទទួលបុណ្យជ្រមុជដោយភ្លើង និងដោយ ព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេពុំបានដឹងទេ"។10

យើងអាចជួយដល់អ្នកដទៃ ឱ្យកាន់តែស្គាល់ការបំផុស គំនិតនៃព្រះវិញ្ញាណ នៅពេលយើងចែកចាយទីបន្ទាល់របស់យើងអំពី ឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរស់នៅរបស់យើង។ ចូរចងចាំថា បទពិសោធន៍មួយចំនួនគឺពិសិដ្ឋខ្លាំងណាស់ដើម្បីប្រាប់។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការចែកចាយទីបន្ទាល់អំពី ព្រះវិញ្ញាណនៅក្នុងជីវិតរបស់យើង នោះអ្នកទាំងឡាយដែលមិន ស្គាល់ការបំផុសគំនិត ទាំងនេះ គឺហាក់ដូចជាកាន់តែស្គាល់ នៅពេលពួកគេមានអារម្មណ៍ស្រដៀងគ្នានេះ។

ខ្ញុំគឺជាសមាជិកដំបូងគេក្នុងគ្រួសាររបស់ខ្ញុំដែលចូលរួមក្នុងសាសនាចក្រ។ កាលពីនៅអាយុប្រាំបីឆ្នាំ ខ្ញុំរង់ចាំដើម្បីទទួលអារម្មណ៍ ខុសប្លែកមួយ ដោយសារតែពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ។ តាមពិតទៅ រឿងតែមួយគត់ដែលខ្ញុំទទួលអារម្មណ៍ នៅពេលខ្ញុំត្រូវ លើកចេញពីទឹកវិញ... គឺទទឹកជោគអស់។ ខ្ញុំបានគិតអំពីអ្វីមួយដែលកាន់តែមានអានុភាពនឹងកើតឡើង នៅពេលខ្ញុំត្រូវបានទទួល ពិធីបញ្ជាក់។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការទទួល ព្រះវិញ្ញាណបរិសុទ្ធ ខ្ញុំមានអារម្មណ៍សប្បាយម្តងទៀត ប៉ុន្តែគ្មានអ្វីខុស ប្លែកជាក់លាក់ ជាងដែលខ្ញុំមាននៅប៉ុន្មាននាទីមុននេះនោះទេ។

វាមិនមានអ្វីទេ រហូតដល់ថ្ងៃបន្ទាប់ពេលក្នុងការប្រជុំតមអាហារ និងថ្លែងទីបន្ទាល់ ទើបខ្ញុំ ទទួលបទពិសោធន៍នូវអ្វីដែលខ្ញុំនៅពេលនេះស្គាល់ថា ជាឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។ បងប្រុសម្នាក់បានឈរថ្លែងទីបន្ទាល់របស់គាត់ ហើយប្រាប់អំពីពរជ័យទាំងឡាយនៃភាពជាសមាជិករបស់គាត់នៅក្នុងសាសនាចក្រ។ ខ្ញុំមានអារម្មណ៍កក់ក្ដៅនៅក្នុងខ្លួនខ្ញុំ។ ទោះជា ខ្ញុំមានអាយុប្រាំបីឆ្នាំ តែខ្ញុំស្គាល់ថា នេះគឺជាអ្វីមួយដែលខុសប្លែក។ ខ្ញុំមានអារម្មណ៍សុខសាន្តមកលើខ្ញុំ ហើយខ្ញុំមានអារម្មណ៍ច្បាស់ថាព្រះវរបិតាសួគ៌បានសព្វព្រះទ័យនឹងខ្ញុំ។

**ផ្ដល់បរិយាកាសមួយ ដែលអាចទទួលអារម្មណ៍ ព្រះវិញ្ញាណ**

មានកន្លែងជាច្រើន ដែលវាកាន់តែងាយស្រួលដើម្បីទទួលអារម្មណ៍ព្រះវិញ្ញាណ។ កន្លែងមួយចំនួនទាំងនោះរួមមានការប្រជុំថ្លែងទីបន្ទាល់ និងសន្និសីទទូទៅ។ ប្រាកដណាស់ ព្រះវិហារបរិសុទ្ធគឺជាកន្លែងមួយទៀត។ សំណូមពរសំរាប់យើងម្នាក់ៗគឺត្រូវផ្ដល់នូវបរិយាកាស ដែលអាចទទួលអារម្មណ៍ព្រះវិញ្ញាណបរិសុទ្ធជាប្រចាំ នៅក្នុងគេហដ្ឋានរបស់យើង និងមានជាប្រចាំសប្ដាហ៍នៅក្នុងព្រះវិហារ។

មូលហេតុមួយ ដែលយើងត្រូវបានលើកទឹកចិត្តឱ្យអធិស្ឋាន និងអានព្រះគម្ពីរជាប្រចាំថ្ងៃ គឺថាសកម្មភាពទាំងពីរនេះអញ្ជើញឱ្យព្រះវិញ្ញាណចូលមកក្នុងគេហដ្ឋានរបស់យើង ហើយនឹងនៅក្នុងជីវិតរស់នៅនៃសមាជិកគ្រួសាររបស់យើង។

ដោយសារតែព្រះវិញ្ញាណ ត្រូវបានពិពណ៌នាជាញឹកញាប់ថាជា សម្លេងតូចរហៀង 11 នោះ វាគឺជាការសំខាន់ ដើម្បីយើងមានពេលស្ងប់ស្ងាត់នៅក្នុងជីវិតរស់នៅរបស់យើងផងដែរ។ ព្រះអម្ចាស់បានទូន្មានដល់យើងថា "ចូរបង្អង់សិន ឱ្យបានដឹងថា យើង*ជា*ព្រះ"12 បើសិនជាយើងផ្ដល់ពេលស្ងប់ ហើយស្ងាត់ស្ងៀមជារៀងរាល់ថ្ងៃ នៅពេលយើងកុំបើក ទូរទស្សន៍ កុំព្យូទ័រ ល្បែងវីដេអូ និងគ្រឿងអេឡិចត្រូនិចផ្ទាល់ខ្លួនរបស់យើងជានិច្ចទេ នោះយើងអនុញ្ញាតឱ្យសម្លេងតូចរហៀងនោះ មានឱកាសដើម្បីផ្ដល់វិវរណៈផ្ទាល់ខ្លួន ហើយខ្សឹបប្រាប់នូវការណែនាំដ៏ផ្អែមល្ហែម ការអះអាង និងលួងលោមដល់យើង។

ស្រដៀងគ្នានេះ យើងអាចផ្ដល់បរិយាកាសនៅព្រះវិហារ ដែលអនុញ្ញាតឱ្យព្រះវិញ្ញាណ ផ្ដល់ការបញ្ជាក់ដ៏ទេវភាព ចំពោះអ្វីដែលកំពុងត្រូវបានបង្រៀន។ ពួកគ្រូបង្រៀន និងពួកអ្នកដឹកនាំ ធ្វើច្រើនជាងគ្រាន់តែបង្រៀនមេរៀន ឬដឹកនាំការប្រជុំ។ ពួកគាត់សម្រួលឱ្យមានការខ្សឹបប្រាប់នៃព្រះវិញ្ញាណចំពោះសមាជិកម្នាក់ៗ។ អែលឌើរ រីឆាដ ជី ស្កត បានមានប្រសាសន៍ថា "បើសិនជាអ្នកគ្មានសម្រេចបានអ្វីនៅក្នុងទំនាក់ទំនង របស់អ្នកជាមួយនឹងសិស្ស ក្រៅពីជួយឱ្យពួកគេស្គាល់ និងធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ នោះអ្នកនឹងប្រទានពរដល់ជីវិតពួកគេដ៏លើសលប់ ហើយអស់កល្បជានិច្ច"។13

គ្រូបង្រៀនថ្នាក់សាន់បីមបានសុំសមាជិកក្នុងថ្នាក់របស់គាត់ម្នាក់ៗម្ដងមួយៗនឹងភ្ជួយ ដើម្បីបង្រៀនពួកគេ អំពីអារម្មណ៍នៃព្រះ-វិញ្ញាណមានដូចជាការលួងលោម និងភាពសុខសាន្តនៃអ្វីដែលបានគ្រប់ដណ្ដប់ពីលើពួកគេនោះ។ ម្ដាយដែលមកជាមួយ ក៏បានស្ដាប់ឮមេរៀនផងដែរ។

ជាច្រើនខែក្រោយមក អ្នកម្តាយនោះមានអំណរគុណ ចំពោះគ្រូបង្រៀន។ គាត់បានប្រាប់ពីមូលហេតុដែល គាត់បានក្លាយជាអ្នកអសកម្ម នៅពេលគាត់បានទៅជាមួយនឹងកូនស្រីតូចរបស់គាត់ ទៅកាន់ថ្នាក់កុមារ។ អស់រយៈពេលជាច្រើនសប្តាហ៍បន្ទាប់ពីមេរៀននោះ អ្នកម្តាយម្នាក់នោះបានរងទុក្ខនឹងការរលូតកូន។ គាត់បានយកឈ្នះលើការសោកសៅ នៅពេលគាត់ទទួលអារម្មណ៍កក់ក្តៅ និងសេចក្តី- សុខសាន្តដ៏អស្ចារ្យនៅវេលានោះ។ វាមានអារម្មណ៍ដូចជាមាននរណាម្នាក់បានដណ្តប់ភួយដ៏កក់ក្តៅដល់គាត់។ គាត់បានស្គាល់ ការលួងលោមពីព្រះវិញ្ញាណ ហើយដឹងថាព្រះវរបិតាសួគ៌ដឹងអំពីគាត់ ហើយថាទ្រង់ស្រឡាញ់គាត់។

នៅពេលយើងយល់អំពីការខ្សឹបប្រាប់នៃព្រះវិញ្ញាណ នោះយើងនឹងអាចស្តាប់ទ្រង់បង្រៀនយើងអំពី "ការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្តីសុខសាន្តនៃនគរ" 14 ហើយនឹង "អ្វីៗគ្រប់យ៉ាងដែល [យើង] ត្រូវធ្វើ"។ 15 យើងនឹងស្គាល់ចម្លើយចំពោះការអធិស្ឋានរបស់យើង ហើយស្គាល់របៀបដើម្បីរស់នៅតាមដំណឹងល្អឱ្យកាន់តែពេញលេញរៀងរាល់ថ្ងៃ។ យើងនឹងត្រូវបានដឹកនាំ និងការពារ។ ហើយយើងអាចបណ្តុះអំណោយទាននេះនៅក្នុងជីវិតរស់នៅរបស់យើង នៅពេលយើងធ្វើតាមការបំផុសគំនិតខាងវិញ្ញាណទាំងនោះ។ ដែលសំខាន់បំផុត យើងនឹងទទួលអារម្មណ៍ថា ទ្រង់ធ្វើជាសាក្សីដល់យើងអំពីព្រះវរបិតា និងព្រះរាជ-បុត្រា។ 16

កាលពីខ្ញុំនៅក្មេង ខ្ញុំបានចូលរួមសន្និសីទយុវវ័យ ខ្ញុំបានទទួលអារម្មណ៍ថា ព្រះវិញ្ញាណបានធ្វើជាសាក្សីចំពោះខ្ញុំអំពីសេចក្តីពិតពេញលេញនៃដំណឹងល្អដែលបានស្តារឡើងវិញ។ នៅក្នុងការរៀបចំសំរាប់ការប្រជុំថ្លែងទីបន្ទាល់ យើងបានច្រៀងបទ "ព្រះវិញ្ញាណនៃព្រះ" ឥឡូវនេះ ខ្ញុំបានច្រៀងទំនុកដំកើងនោះជាច្រើនដងកាលពីមុន នៅក្នុងការប្រជុំសាក្រាម៉ង់។ ប៉ុន្តែនៅក្នុងឱកាសនេះចាប់តាំងពីការបើកកម្មវិធី ខ្ញុំបានទទួលអារម្មណ៍នៃព្រះវិញ្ញាណ។ ដល់ពេលយើងបានច្រៀងបទ "the latter-day glory begins to come forth" (សិរីល្អនៃថ្ងៃចុងក្រោយ ចាប់ផ្តើមចេញមក) 17 ខ្ញុំបានដឹងថា ពាក្យពេចន៍ទាំងនេះគឺមានន័យច្រើនជាង ទំនុកច្រៀងដ៏ល្អៗទៅទៀត ព្រោះវាជាសេចក្តីពិតដ៏ស្រស់ស្អាត។

ព្រះវិញ្ញាណបរិសុទ្ធបានបញ្ជាក់ដល់ខ្ញុំថា ព្រះ ជាព្រះវរបិតាមានព្រះជន្មរស់។ ទ្រង់ស្រឡាញ់យើងម្នាក់ៗ។ ទ្រង់ស្គាល់យើងម្នាក់ៗ និងដោយផ្ទាល់។ ទ្រង់ស្តាប់ឮការអង្វរនៅក្នុងដួងចិត្តរបស់យើង ហើយទ្រង់ឆ្លើយតបការអធិស្ឋានដោយស្មោះស្ម័គ្រទាំងឡាយ។

ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង។ ទ្រង់យាងមកផែនដីនៅក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុតដើម្បីធ្វើឱ្យធួនសំរាប់អំពើបាបរបស់យើង។ ហើយទ្រង់នឹងយាងមកម្តងទៀត។ ទិដ្ឋភាពនៃដំណឹងល្អទាំងនេះ និងដទៃទៀតធ្វើឱ្យទីបន្ទាល់របស់ខ្ញុំបានរឹងមាំនៅក្នុងដួងចិត្តរបស់ខ្ញុំ ដោយសារតែឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សូមមើល គ. និង ស. 68:25។
2. មរ៉ូណៃ 7:16។

3. សូមមើល *ពិតចំពោះសេចក្ដីជំនឿ* ( ឆ្នាំ 2004) ទំព័រ 83 ។

4. ហេលេមិន 4:24 ។

5. គ. និង ស. 121:45--46 ។

6. គ. និង ស. 8:2 ។

7. អេណុស 1:10 ។

8. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* 3:381 ។

9. Henry B. Eyring, “Gifts of the Spirit for Hard Times,” *Ensign*, ខែ មិថុនា ឆ្នាំ 2007, 18 ។

10. នីហ្វៃទី 3 9:20 ។

11. សូមមើល ពង្សាវតារក្សត្រទី 1 19:12; នីហ្វៃទី 1 17:45 គ. និង ស. 85:6 ។

12. ទំនុកដំកើង 46:10 សូមមើល គ. និង ស. 101:16 ផងដែរ ។

13. រីឆាដ ជី ស្កត *Helping Others to Be Spiritually Led* ( សុន្ទរកថាទៅកាន់គ្រូបង្រៀនខាងសាសនា ថ្ងៃទី 11 ខែ សីហា ឆ្នាំ 1998) ទំព័រ 3 នៅក្នុង *Teaching, No Greater Call* ឆ្នាំ 1999 ទំព័រ 48 ។

14. គ. និង ស.36:2 ។

15. សូមមើល នីហ្វៃទី 2  32:1--5 ។

16. សូមមើល នីហ្វៃទី 2 31:18 ។

17. "ព្រះវិញ្ញាណនៃព្រះ" *ទំនុកដំកើង* ទំព័រ 28 ។